សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា ( ស.យ.ជ.ក )
Cambodia Indigenous Youth Association ( CIYA )
Address: #392, St. 10M, Group 06, Prektoal Village, Sangkat Stung Meanchey, Khan Meanchey, Phnom Penh
Tel: (+855) 12 829 717 | Email: info@ciyanet.org | Website: www.ciyanet.org

# ដំណឹងជ្រើសរើសបុគ្គលិក

**សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា(ស.យ.ជ.ក)** ត្រូវបានបង្កើតឡើងដោយក្រុមនិស្សិតជនជាតិដើមភាគតិចមួយក្រុម ដែលបានមកសិក្សានៅរាជធានីភ្នំពេញក្នុងឆ្នាំ២០០៥ ដោយបានចុះបញ្ជីរទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ យោងតាម ស.ជ.ណ លេខ ១១៦៩ និងសំណើសុំទទួលស្គាល់សមាសភាពក្រុមប្រឹក្សាភិបាល គណៈកម្មការប្រតិបត្តិថ្មីនៃរចនាសម្ព័ន្ធ ប្តូរលក្ខន្តិកៈ និងប្តូរអាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ យោងតាម ស.ជ.ណ លេខ ១៩៩៤។ គោលបំណងក្នុងការបង្កើតក្រុមយុវជននេះឡើងគឺដើម្បីចងក្រងក្រុមយុវជនជនជាតិដើមភាគតិច និង បង្កើនភាពសកម្មរបស់ពួកគាត់ក្នុងការចូលរួមកិច្ចការងារសង្គមជាពិសេសការងារពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ឲ្យយុវជនចេះធ្វើការរួមគ្នាដើម្បីថែរក្សា អភិវឌ្ឍសហគមន៍ និងវប្បធម៌ជនជាតិដើមភាគតិចឲ្យបានគង់វង់។ សមាគមមានគោលដៅផ្តោតទៅលើការបង្កើនសមត្ថភាពរបស់យុវជនតាមរយៈការចូលរួមក្នុងការអប់រំជាន់ខ្ពស់ និងលទ្ធភាពបង្កើនចំណេះ និងជំនាញវិជ្ជាជីវៈ ព្រមទាំងចំណេះដឹងប្រពៃណីជនជាតិដើមភាគតិច ដើម្បីផ្តល់លទ្ធភាពឲ្យពួកគាត់អាចចូលរួមចំណែកក្នុងការអភិរក្ស និងអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិចប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល។ សមាគមមានតំបន់គោលដៅចំនួន៩ ខេត្ត/ក្រុង រួមមានខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ កំពង់ស្ពឺ និងរាជធានីភ្នំពេញ។

បច្ចុប្បន្ន ស.យ.ជ.ក ត្រូវការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពក្នុងការបំពេញការងារក្នុងមុខតំណែងជា **"ជំនួយការគម្រោង"** ចំនួន **១រូប** ដើម្បីអនុវត្តការងារនៅគម្រោង **ការអប់រំសម្រាប់យុវជន និងចំណេះដឹងប្រពៃណី** ដែលមានទីតាំងនៅខេត្តរតនគិរី។ បុគ្គលិកដែលបានជ្រើសរើសត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោយៈ

| | |
|---|---|
| **តួនាទី** | **ជំនួយការគម្រោង** |
| **ទីតាំងការងារ** | **សង្កាត់យក្ខឡោម ខេត្តរតនគិរី និងតំបន់គោលដៅរបស់សមាគម** |
| **របាយការណ៍ជូន** | **ប្រធានកម្មវិធី** |

## <u>ភារកិច្ច និងការទទួលខុសត្រូវៈ</u>

- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកា និងសកម្មភាពនានា
- សម្របសម្រួលសហគ្រាសផលិត ឬតម្បាញបែបប្រពៃណី និងអាជីវកម្មយុវជនខ្នាតតូច
- សម្របសម្រួលបង្កើតក្រុមសន្សំប្រាក់ ក្រុមសិល្បៈ និងក្រុមតម្បាញ ជាមួយសមាជិក និងក្រុមយុវជន
- សម្របសម្រួលឲ្យមានការចូលរួមពីសមាជិកក្នុងការល្បាតព្រៃតំបន់ការពារធម្មជាតិបឹងយក្ខឡោម

- ដឹកនាំ ឬសម្របសម្រួលកម្មវិធីស្វ័យសិក្សារបស់សមាជិកដើម្បីឲ្យសមាជិកបានចែករំលែកពីចំណេះដឹងវិទ្យាសាស្ត្រ ការរៀនសូត្រពីជំនាញកុំព្យូទ័រ ភាសាជនជាតិដើមភាគតិច ភាសាអង់គ្លេស ចំណេះដឹងប្រពៃណីផ្សេងៗទៀតជាមួយសមាជិកនៅរតនគិរី ឬសមាជិកនៅភ្នំពេញ
- សម្របសម្រួលការកត់ត្រាពីចំណេះដឹង និងសិក្សាស្រាវជ្រាវពាក់ព័ន្ធវប្បធម៌ ប្រពៃណីរបស់ជនជនជាតិដើមភាគតិច ដូចជា ការគ្រប់គ្រងព្រៃឈើ កីឡា គ្រាប់ពូជ រឿងនិទាន និងវិធានប្រពៃណី
- ជួយសម្របសម្រួលឲ្យមានវគ្គបណ្តុះបណ្តាលពីចំណេះដឹងរបស់ចាស់ទុំទៅកាន់យុវជនដែលជាសមាជិកនៅរតនគិរី ពិសេសយុវជននៅសង្កាត់យក្ខឡោម។ ចំណេះដឹងទាំងនេះរួមមាន ថ្នាក់រៀនភាសារជនជាតិដើមភាគតិច តម្បាញ សិល្បៈ និងគំនូរជាដើម
- សម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសរបស់សមាជិក និងរៀបចំកម្មវិធីប្រកួតប្រជែងចំណេះដឹងប្រពៃណីរបស់យុវជនដូចជា លទ្ធផលស្រាវជ្រាវ ប្រកួតសិល្បៈតន្ត្រី ការសរសេរអក្សរ ឬគំនូរតាមបែបជនជាតិដើមភាគតិច
- សម្របសម្រួលឲ្យមានវគ្គសិក្សាពីការប្រើប្រាស់ និងសុវត្ថិភាពបណ្តាញសង្គម ដើម្បីយុវជនអាចចូលរួមផ្សព្វផ្សាយពីការងារសហគមន៍ប្រកបដោយសុវត្ថិភាព
- រៀបចំសំណើបុរេប្រទានសម្រាប់ចំណាយលើសកម្មភាពគម្រោងឲ្យបានត្រឹមត្រូវតាមខ្នង់ថវិកា និងគោលនយោបាយ
- ផ្សព្វផ្សាយ និងពន្យល់ណែនាំពីលក្ខន្តិកៈ និងគោលនយោបាយនានារបស់សមាគមទៅដល់សមាជិក
- ជួយសម្របសម្រួលការផ្តួចផ្តើមរបស់សមាជិក (ឧ.ចម្ការរួម និងសកម្មភាពផ្សេងៗទៀត)
- រៀបចំផែនការសកម្មភាព និងរបាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- អនុវត្តកិច្ចការងារទៅតាមការស្នើសុំរបស់ក្រុមយុវជន និងអ្នកគ្រប់គ្រង។

## <u>ជំនាញ ចំណេះដឹង និងបទពិសោធន៍៖</u>

- បញ្ចប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ឬសញ្ញាប័ត្រ ឬជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍យ៉ាងតិច១ឆ្នាំ ធ្វើការក្នុងវិស័យការងារពាក់ព័ន្ធទៅនឹងការចងក្រង និងបណ្តុះបណ្តាលយុវជន ឬសហគមន៍
- យល់ដឹងទូលំទូលាយអំពីចំណេះប្រពៃណី និងស្ថានភាពបរិបទរបស់ជនជាតិដើមភាគតិចនៅខេត្តរតនគិរី
- មានចំណេះដឹង និងជំនាញមូលដ្ឋានក្នុងការវិភាគ ស្វែងរកឬសគល់ និងដោះស្រាយបញ្ហានានា
- អាចដឹកនាំ និងសម្របសម្រួលគំនិតផ្តួចផ្តើមរបស់យុវជន ពិសេសលើការចងក្រងយុវជន ការចែករំលែកចំណេះដឹងវប្បធម៌ប្រពៃណី ព្រមទាំងការអភិរក្ស និងអភិវឌ្ឍការងារយុវជន
- មានចំណេះដឹងលើការគ្រប់គ្រង តាមដាន និងវាយតម្លៃកិច្ចការងារគម្រោង
- ចេះនិយាយភាសាជនជាតិដើមភាគតិចបានស្ទាត់ជំនាញយ៉ាងតិចចំនួន១ (ចេះភាសាទំពួនកាន់តែល្អប្រសើរ)
- ចេះសរសេរ អាន និងនិយាយភាសាខ្មែរបានស្ទាត់ជំនាញ
- អាចនិយាយ អាន និងសរសេរភាសាអង់គ្លេសខ្លះៗកាន់តែល្អ។

## <u>គុណសម្បត្តិ និងអត្តចរិត៖</u>

- ជាជនជាតិដើមភាគតិចរស់នៅខេត្តរតនគិរី ដែលមានអាយុ១៨ឆ្នាំឡើងទៅ
- មានភាពស្មោះត្រង់ សុភាពរាបសារ រួសរាយរាក់ទាក់ ចេះសាមគ្គី និងមានស្មារតីធ្វើការងារជាក្រុម
- មិនប្រកាន់ រើសអើងពូជសាសន៍ ពណ៌សម្បុរ ឬភាពខុសគ្នានៃជនជាតិដើមភាគតិចនីមួយៗ

- ចេះគោរព ស្រលាញ់ ប្រតិបត្តិ អភិវឌ្ឍ អភិរក្សនូវវប្បធម៌ ប្រពៃណី និងអត្តសញ្ញាណជនជាតិដើមភាគតិច
- អាចរៀនសូត្រពីការងារថ្មីៗ និងបំពេញការងារប្រកដដោយភាពបត់បែនឲ្យបានទាន់ពេលវេលា
- មានការតាំងចិត្ត លះបង់ខ្ពស់ និងអាចធ្វើការក្រោមសម្ពាធការងារបាន
- មានគំនិតស្ថាបនា និងអាចដោះស្រាយបញ្ហាបានទាន់ពេលវេលា
- មានភាពឯករាជ្យក្នុងការបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយមិនចាំបាច់មានការគ្រប់គ្រងច្រើនពីថ្នាក់ដឹកនាំ
- អាចស្នាក់នៅក្នុងសហគមន៍ និងមានភាពបត់បែនទៅតាមស្ថានភាពជាក់ស្តែង ដោយអាចធ្វើកិច្ចការងារនៅថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកពិធីបុណ្យផ្សេងៗបាន
- មានម៉ូតូខ្លួនឯងសម្រាប់ប្រើប្រាស់ និងអាចធ្វើដំណើរនៅក្នុងស្ថានភាពផ្លូវលំបាក
- មានទស្សនៈវិស័យតាមបែបសមូហភាពរបស់ជនជាតិដើមភាគតិច។

**<u>ប្រាក់ខែ និងអត្ថប្រយោជន៍៖</u>**

- ប្រាក់ខែ (អាស្រ័យលើសមត្ថភាព និងបទពិសោធន៍)
- មានប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្មបុគ្គលិក
- មានកាតទូរស័ព្ទចំនួន ៥ ដុល្លាអាមេរិក/ខែ
- ទទួលបានការបណ្តុះបណ្តាលកសាងសមត្ថភាពជាប្រចាំ និងមានអត្ថប្រយោជន៍ផ្សេងៗទៀត។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូប(CV) និងលិខិតចំណាប់អារម្មណ៍(Cover Letter) មកកាន់អាសយដ្ឋានអ៊ីម៉ែល info@ciyanet.org និង sotha@ciyanet.org ឬមកកាន់ការិយាល័យសមាគមផ្ទាល់ដែលមានអាសយដ្ឋានផ្ទះលេខ ២៨ ផ្លូវ៤៦០ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬទំនាក់ទំនងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខ ០១២ ៨២៩ ៧១៧/០៨៨ ៦២០៩ ៥៥៥ ។

**<u>បញ្ជាក់</u>៖** មានតែបេក្ខជនដែលត្រូវបានជ្រើសរើសក្នុងវគ្គជម្រុះប្រវត្តិរូបសង្ខេបប៉ុណ្ណោះ ដែលនឹងទទួលបានការអញ្ជើញឲ្យមកចូលរួមធ្វើបទសម្ភាសន៍ការងារ។

- **កាលបរិច្ឆេទឈប់ទទួលពាក្យ៖ *ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ (ត្រឹមម៉ោង ៥:០០ល្ងាច)***
- **កាលបរិច្ឆេទសម្ភាសន៍៖ *ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១***

*<u>*សមាជិកសមាគម និងស្ត្រីជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្ត!</u>*